សារណាជាការឆ្លើយតបចំពោះ

**ការអំពាវនាវឲ្យចូលរួមជាគំនិត សម្រាប់មុខងារនៅសេសសល់ របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ទាក់ទងនឹងជនរងគ្រោះ**

**ជូនចំពោះ÷** លោកចៅក្រម យូរ ឧត្តរា

លោកស្រីចៅក្រម Claudia FENZ

**ផ្ញើរជូនដោយ÷** Dr. Maria Elander[1]

Dr. Rachel Hughes[2]

Mr. Kimsan Soy[3]

Dr. Christoph Sperfeldt[4]

**កាលបរិច្ឆេទ÷** ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

យើងខ្ញុំសូមផ្ញើរជូននូវសារណានេះ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ដែលមានបទពិសោធន៍ស្រាវជ្រាវរយៈពេលវែង ពាក់ព័ន្ធដំណើរការរបស់ អ.វ.ត.ក។ យើងខ្ញុំសូមយកឱកាសនេះ ដើម្បីចែករំលែកនូវគំនិតមួយចំនួន សម្រាប់ការពិចារណារបស់ចៅក្រមរបាយការណ៍ ដោយផ្អែកលើការស្រាវជ្រាវកន្លងមករបស់យើងខ្ញុំ និងកិច្ចសហការជាច្រើនផ្សេងៗគ្នា ជាមួយដៃគូកម្ពុជា។ ក្នុងនាមជាអ្នកស្រាវជ្រាវ យើងខ្ញុំមិនមានតួនាទី ក្នុងការស្នើឡើងនូវគំនិតផ្តួចផ្តើមជាក់លាក់ឡើយ។ ប៉ុន្តែយើងខ្ញុំសូមលើកជា**ឱកាស និងគោលការណ៍ណែនាំខ្លះ** ដែលយើងខ្ញុំជឿជាក់ថា នឹងអាចជួយដល់ការចាប់ផ្តើម គំនិតផ្តួចផ្តើមទាក់ទងជនរងគ្រោះ ដែលសមស្របនិងមានប្រសិទ្ធិភាព ដែលត្រូវគាំទ្រនិងសម្របសម្រួលដោយមុខងារនៅសេសសល់របស់ អ.វ.ត.ក។

*ជាដំបូង គំនិតផ្តួចផ្តើមដែលបង្កើតឡើង ស្ថិតក្រោម ឬត្រូវសម្របសម្រួលដោយមុខងារនៅសេសសល់របស់ អ.វ.ត.ក គួរធ្វើការពិចារណា និង/ឬ* ***បង្កើតឡើងផ្អែកលើគំនិតផ្តួចផ្តើមដែលកំពុងដំណើរការ ឬមានពីពេលកន្លងមក*** *ដែលត្រូវបានអនុវត្តដោយ ផ្នែកនានារបស់ អ.វ.ត.ក និងអង្គការសង្គមស៊ីវិលកម្ពុជានានា។*

---

[1] Senior Lecturer, La Trobe Law School, La Trobe University
[2] Senior Lecturer in Human Geography, School of Earth Sciences, University of Melbourne
[3] Director, Center for the Study of Humanitarian Law, Royal University of Law and Economics
[4] Honorary Fellow, Melbourne Law School

កេរ្តិ៍តំណែលដ៏សំខាន់របស់ អ.វ.ត.ក គឺការគាំទ្រដែល អ.វ.ត.ក បានផ្តល់សម្រាប់ការបង្កើត គំនិតផ្តួចផ្តើមជាច្រើនដែលផ្តោតលើជនរងគ្រោះ នៅអំឡុងពេលពីរទសវត្សរ៍កន្លងមក។ សង្គមស៊ីវិលកម្ពុជា គឺជាកម្លាំងជម្រុញសម្រាប់គំនិតនេះ។ ការនេះលេចចេញជាក់ច្បាស់ នៅក្នុងមធ្យោបាយសំណងសមូហភាព ដែលទទួលស្គាល់ដោយ អ.វ.ត.ក។ អាណត្តិការងារនៃមុខងារនៅសេសសល់របស់ អ.វ.ត.ក ក្នុងផ្នែកនេះ គឺឱកាសក្នុងការ**បន្តលើកកម្ពស់ ឬពង្រីកបន្ថែមទៀត ទៅលើគំនិតផ្តួចផ្តើមដែលទទួលបានជោគជ័យទាំងអស់នេះ**។ ក្នុងន័យនេះ វិធីសាស្ត្របែបសហការណ៍ តាំងពីចាប់ផ្តើមដំបូង ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗរបស់កម្ពុជា ជាពិសេសគឺសង្គមស៊ីវិល គឺជារឿងចាំបាច់។ វិធីសាស្ត្របែបនេះគួរដំណើរការលើសពីការប្រឹក្សាត្រឹមម្តងម្កាល ហើយត្រូវមានការចូលរួមពាក់ព័ន្ធ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដែលយន្តការនៅសេសសល់ អាចចាប់ផ្តើមតួនាទីដំបូង។ ការនេះមិនត្រឹមតែជៀសផុតពីការប្រជែងគ្នា យកមូលនិធិពីអ្នកផ្តល់ជំនួយសំខាន់ៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមចំណែក ដល់ការបំពាក់នូវជំនាញសម្រាប់គំនិតផ្តួចផ្តើមប្រកបដោយចិរភាពជាងមុន។ សូមមើលឧបសម្ព័ន្ធ ក សម្រាប់បញ្ជីសង្ខេបនៃបណ្តាអង្គការនានា។

*ទីពីរ គំនិតផ្តួចផ្តើមទាំងអស់នេះ គួរសិក្សាពីបទពិសោធន៍កន្លងមក ហើយរួមចំណែកដល់ការបង្រួបបង្រួម និងផ្សព្វផ្សាយចំណេះដឹងដែលអាចជួយដល់មុខងារក្រោយពេលសេសសល់ ទាក់ទងនឹងជនរងគ្រោះនាពេលអនាគត។*

ក្នុងរយៈពេលច្រើនឆ្នាំកន្លងមក ការផ្សព្វផ្សាយ ជំនួយដល់ជនរងគ្រោះ សំណង និងវិធានការក្រៅផ្លូវតុលាការជាច្រើនផ្សេងៗគ្នា បានបង្កើតឡើងនូវបណ្តុំជំនាញ ចំណេះដឹង មេរៀន និងឧត្តមានុវត្ត យ៉ាងសម្បូរបែប ទាក់ទងនឹងការគោរព ផលប៉ះពាល់ និងការឆ្លើយតប ក្នុងការបំពេញការងារជាមួយជនរងគ្រោះ និងអ្នកនៅរស់ពីរបបខ្មែរក្រហម ទាំងនៅក្នុងនិងនៅក្រៅតុលាការ។ ការនេះបានពង្រីក និងធ្វើឱ្យសំបូរបែបយ៉ាងខ្លាំង នូវមូលដ្ឋានចំណេះដឹងរបស់យើង សម្រាប់ការងារពាក់ព័ន្ធជនរងគ្រោះ។ ប៉ុន្តែភាគច្រើននៃចំណេះដឹងបែបនេះ គឺនៅរាយប៉ាយពីគ្នា ហើយភាគច្រើនមិនអាចរកបានជាសាធារណៈ ឬស្ថិតក្នុងហានិភ័យនៃការបាត់បង់ (ដូចជានៅពេលអង្គការមិនមែនរដ្ឋាភិបាល និងគេហទំព័ររបស់ពួកគេត្រូវបិទ បុគ្គលិកប្តូរចេញ ឯកសារឌីជីថល នៃសម្ភារៈដែលមានតម្លៃ និងឯកសាកាលប្បវត្តិ មិនអាចរកបានឬបាត់បង់)។ មុខងារនៅសេសសល់របស់ អ.វ.ត.ក អាចរួមចំណែកដល់ការបញ្ចូលគ្នា រក្សា និងផ្សព្វផ្សាយជាសាធារណៈ នូវចំណេះដឹង និងប្រភព ដែលមាន

សក្តានុពល ក្នុងការផ្តល់ព័ត៌មានដល់គំនិតផ្តួចផ្តើមផ្នែកអប់រំ និងទាក់ទងជនរងគ្រោះកម្ពុជា និងមុខងារក្រោយពីភាពសេសសល់ និងក្រោយបញ្ចប់ អ.វ.ត.ក។ ភារកិច្ចបែបនេះអាចមានលទ្ធភាព ត្រូវបានសម្របសម្រួល ឬជួយបន្ថែម ចំពោះមុខងារបណ្ណាសាររបស់ខ្លួន។ ការងារផ្ទៀងផ្ទាត់ និងរក្សាសម្ភារៈទាំងនេះខ្លះ កំពុងត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់-អ.វ.ត.ក ប៉ុន្តែការងារនេះនឹងទទួលបានប្រយោជន៍បន្ថែម ពីការផ្តល់មូលនិធិ និងបុគ្គលិក បែបគម្រោងបន្ថែមទៀត។ ការចូលរួមជាមួយបុគ្គលិក ដែលយល់ដឹងពីប្រវត្តិកន្លងមក នៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក អាចផ្តល់ប្រយោជន៍ច្រើន ដល់ការងារដែលកំពុងដំណើរការនេះ។

*ទីបី គំនិតផ្តួចផ្តើម គួររួមចំណែកដល់ការលើកកម្ពស់ កេរ្តិ៍ដំណែលអប់រំរបស់ អ.វ.ត.ក សម្រាប់ប្រទេសកម្ពុជា*

ក្រៅពីការប្រមូលផ្តុំ និងរក្សាទុកនូវចំណេះដឹង ដែលទទួលបានតាមរយៈដំណើរការរបស់ អ.វ.ត.ក គឺមានឱកាសដ៏សំខាន់ ដើម្បីលើកកម្ពស់កេរ្តិ៍ដំណែលអប់រំរបស់ អ.វ.ត.ក ដោយមានប្រយោជន៍សម្រាប់យុវជន អ្នកនៅរស់ និងសាធារណជនទូទៅ។ យើងបានសង្កេតឃើញនូវតម្រូវការធំធេង ក្នុងចំណោមយុវជន និងសិស្សនិស្សិតកម្ពុជា ក្នុងការសិក្សាអំពីអតីតកាល និងអំពី អ.វ.ត.ក។ នៅកម្រិតសាកលវិទ្យាល័យ គ្រូឧទ្ទេសជាច្រើនស្វែងរកឱកាស ក្នុងការកសាងសមត្ថភាព លើប្រធានបទទាំងអស់នេះ ហើយពួកគាត់ចង់ឃើញ ការបញ្ចូលបន្ថែមនៅចំណេះដឹងទាំងនោះ ទៅក្នុងកម្មវិធីសិក្សានៅឧត្តមសិក្សា នៅតាមជំនាញផ្សេងៗគ្នា។ មុខងារនៅសេសសល់ អាចរួមចំណែកដល់ការបញ្ចូល ចំណេះដឹងដែលពាក់ព័ន្ធ ទៅលើផ្នែកអប់រំផ្លូវការ នៅក្នុងប្រទេសកម្ពុជា និងជួយដល់ការផ្សព្វផ្សាយ និង/ឬផលិតព័ត៌មាន ឬសម្ភារៈជាភាសាខ្មែរបន្ថែមទៀត សម្រាប់ការប្រើប្រាស់ក្នុងការរៀន និងបង្រៀន។ ក្នុងបរិបទនេះ លទ្ធភាពចូលពិនិត្យបណ្ណសារ អ.វ.ត.ក គឺមានសារសំខាន់ធំធេងណាស់។

*ទីបួន មានឱកាសសម្រាប់* ***កិច្ចសហការរវាងមុខងារនៅសេសសល់ និងអ្នកស្រាវជ្រាវផ្នែកអប់រំ*** *សម្រាប់គោលបំណងនៃការបង្កើតចំណេះដឹងបន្ថែម អំពីការអនុវត្តទាក់ទងនឹងជនរងគ្រោះនៅ អ.វ.ត.ក និងទីកន្លែងផ្សេងទៀត។*

អ្នកសិក្សាស្រាវជ្រាវ ទាំងនៅក្នុងនិងនៅក្រៅប្រទេសកម្ពុជា បានធ្វើការស្រាវជ្រាវយ៉ាងច្រើន ទៅលើប្រធានបទ និងការអនុវត្តនានាទាក់ទងនឹង អ.វ.ត.ក ដូចជាការស្រាវជ្រាវជាពិសេស អំពីការចូលរួមរបស់ជនរងគ្រោះ និងសំណង (សូមមើលឧបសម្ព័ន្ធ ខ)។ ការស្រាវជ្រាវនេះបានពង្រីកចំណេះដឹង និងការយល់ដឹងអំពីការអនុវត្តទាក់ទងជនរងគ្រោះជាច្រើន ដែលចំណេះដឹងមួយចំនួន មានឥទ្ធិពលទៅលើគំនិតផ្តួចផ្តើមនាពេលក្រោយ។ ប៉ុន្តែនៅតែមានគម្លាតចំណេះដឹងជាច្រើន ដែលដូច្នេះហើយនៅមានវិសាលភាព សម្រាប់ការស្រាវជ្រាវបន្ថែម និងឱកាសសម្រាប់ការសហការក្នុងការស្រាវជ្រាវ លើវិស័យដែលមានផលប្រយោជន៍រួមគ្នា សម្រាប់អ្នកស្រាវជ្រាវ និងមុខងារនៅសេសសល់។

*ចុងក្រោយ ដោយសារតែលក្ខណៈបែបអន្តរកាល និងបណ្តោះអាសន្ន នៃមុខងារនៅសេសសល់ ក្នុងករណីដែលអាចធ្វើបាន គំនិតផ្តួចផ្តើម**ដឹកនាំដោយកម្ពុជា** ដោយមានការចូលរួមពីតួអង្គកម្ពុជាផ្សេងៗគ្នា ហើយត្រូវធានាថាអ្នកនៅរស់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង ត្រូវបានប្រឹក្សា និងផ្តល់យោបល់។*

ការផ្លាស់ប្តូរចេញនូវជំនួយរបស់អង្គការសហប្រជាជាតិ និងជំនួយអន្តរជាតិដទៃទៀត គឺជាឱកាសមួយក្នុងការទទួលស្គាល់បន្ថែម និងពង្រឹងទៅលើភាពជាអ្នកដឹកនាំរបស់កម្ពុជា ក្នុងគំនិតផ្តួចផ្តើមទាក់ទងជនរងគ្រោះ នៅក្នុងដំណាក់កាលនៅសេសសល់នេះ។ តួនាទីចម្បងនៃមុខងារនៅសេសសល់ អាចជួយដល់ការសម្របសម្រួល និងគាំទ្រដល់ភាពជាអ្នកដឹកនាំបែបនេះ នៅក្នុងគ្រប់សកម្មភាពទាំងអស់របស់ខ្លួន។ នៅទីនេះ យើងខ្ញុំសូមសង្កត់ធ្ងន់ទៅលើ សារសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដទៃទៀត នៅក្នុងដំណើរការ ដោយកត់សម្គាល់ពីការថយចុះយ៉ាងខ្លាំងនូវសកម្មភាពផ្សព្វផ្សាយ របស់សង្គមស៊ីវិលនិង អ.វ.ត.ក ក្នុងអំឡុងដំណើរការសវនាការតួចពីរ ក្នុងសំណុំរឿង ០០២ នេះ។

យើងខ្ញុំរង់ចាំជានិច្ចក្នុងការប្រឹក្សាបន្ថែម ឬផ្តល់ជូននូវធនធានពាក់ព័ន្ធ និងសម្ភារៈស្រាវជ្រាវនានា ដែលអាចជួយដល់សហចៅក្រមរបាយការណ៍ និង/ឬមុខងារនៅសេសសល់នាពេលអនាគត ដើម្បីបំពេញទៅតាមអាណត្តិការងាររបស់ពួកគេ។

## ឧបសម្ព័ន្ធ ក៖ បញ្ជីសង្ខេបនៃអង្គការសង្គមស៊ីវិលពាក់ព័ន្ធ

*កំណត់សម្គាល់៖ អង្គការមួយចំនួនលែងមានឈ្មោះ ឬលែងដំណើរការហើយ។ ប៉ុន្តែអង្គការទាំងនោះ បានអនុវត្តនូវសកម្មភាពសំខាន់ៗ នៅក្នុងពេលកន្លងមក និង/ឬបានបង្កើតនូវព័ត៌មានដែលមានតម្លៃ (កូនសៀវភៅ ខ្សែភាពយន្ត សម្ភារៈផ្សព្វផ្សាយជាដើម) ឬវិធីសាស្ត្រស្រាវជ្រាវដែលអាចពិចារណា តាមគំនិតផ្តួចផ្តើមដែលគាំទ្រដោយមុខងារនៅសេសសល់។*

សមាគម ANVAYA

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

គំនិតផ្តួចផ្តើមសម្រាប់ភាពយុត្តិធម៌នៅអាស៊ី (KRT Monitor) / មជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ Stanford

មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)

គណៈកម្មាធិការប្រព្រឹត្តកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)

មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងនីតិមនុស្សធម៌ (CSHL), សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)

អង្គការមនុស្សចាស់កម្ពុជា

អង្គការសកម្មភាពសិល្បៈខ្មែរ

វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (KID)

ក្តីករុណា (អតីតមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការផ្សះផ្សា ICfC]

KDKG (សមាគមវប្បធម៌កម្ពុជា អាល្លឺម៉ង់)

ក្បៀមក្សាន្ត

ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)

អង្គការចិត្តសង្គម អន្តរវប្បធម) (TPO) កម្ពុជា

អង្គការការពារសិទ្ធិ ជនជាតិភាគតិច (MIRO)

អង្គការយុវសន្តិភាព (YfP)

អង្គការកម្មវិធី អភិវឌ្ឍន៍ធនធានយុវជន (YRDP)

## ឧបសម្ព័ន្ធ ខ៖ ឯកសារបោះពុម្ពផ្សាយនានា ពាក់ព័ន្ធជនរងគ្រោះ និងសំណងនៅ អ.វ.ត.ក


Elander, Maria, ការកំណត់ជនរងគ្រោះនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ៖រឿងក្តីតុលាការខ្មែរក្រហម (Routledge ឆ្នាំ ២០១៨)

Hughes, Rachel, Maria Elander, Christoph Sperfeldt, Helen Jarvis, William Smith, Lyma Nguyen និង Wendy Lobwein ‘សមិទ្ធិផល និងកេរ្តិ៍តំណែល នៃតុលាការខ្មែរក្រហម៖ ការឆ្លុះបញ្ចាំងពីខាងក្នុងតុលាការ” (ឆ្នាំ ២០១៨ 44(2) *Australian Feminist Law Journal* 303-324.

Hughes, Rachel, “សិទ្ធិរបស់ជនរងគ្រោះ ការរំខានជាសមូហភាព និងខ្លាំងបំផុតរបស់ជនរងគ្រោះ នៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា” (ឆ្នាំ ២០១៦) *Australian Journal of Human Rights 22(2):143-164.*

Killean, Rachel, ជនរងគ្រោះ អំពើសាហាវយង់ឃ្នង់ និងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ៖ មេរៀនពីប្រទេសកម្ពុជា (Routledge 2018)

Manning, Pete, យុត្តិធម៌អន្តរកាល និងការចងចាំនៅកម្ពុជា៖ ហួសពីអង្គជំនុំជម្រះវិសាមញ្ញ (Routledge 2018)

McCaffrie, Caitlin, Somaly Kum, Daniel Mattes, និង Lina Tay, “ដូច្នេះយើងអាចដឹងថាមានអ្វីកើតឡើង"៖ លទ្ធភាពផ្នែកអប់រំរបស់ អ.វ.ត.ក” របាយការណ៍សម្រាប់មជ្ឈមណ្ឌលសិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ សាកលវិទ្យាល័យ Stanford និង East-West Center ខែមករា ឆ្នាំ២០១៨។ https://humanrights.stanford.edu/publications/so-we-can-know-what-happened-educational-potentialeccc

McCaffrie, Caitlin, “កេរ្តិ៍តំណែលអប់រំ៖ការស្វែងរកទំនាក់ទំនង រវាងការអប់រំ និងភាពអត់ធន់នៅ អ.វ.ត.ក” (2020) *Leiden Journal of International Law* 33(4): 975-991.

Sperfeldt, Christoph & Rachel Hughes. ការបង្កើតគម្រោងសំណង *Journal of Human Rights Practice*. 12, 2020, 545-565.

Sperfeldt, Christoph & Oeung Jeudy, ការវិវឌ្ឍន៍នៃការចូលរួម របស់សង្គមស៊ីវិលកម្ពុជា ជាមួយការចូលរួមរបស់ជនរងគ្រោះ នៅតុលាការខ្មែរក្រហម” in Lia Kent, Joanne Wallis, Claire Cronin (eds), *Civil Society and Transitional Justice in Asia and the Pacific* (ANU Press, 2019) 85-105. http://press-files.anu.edu.au/downloads/press/n6044/pdf/ch04.pdf

Sperfeldt, Christoph, “ការផ្សព្វផ្សាយយុត្តិធម៌៖ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ នៅតុលាការខ្មែរក្រហម” (2014) 115 *Asia Pacific Issues,* 1-12. https://www.eastwestcenter.org/publications/broadcasting-justice-mediaoutreach-the-khmer-rouge-trials

Tann Boravin & Khuochsopheaktra Tim, “ភារកិច្ចដែលមិនត្រូវបំភ្លេច” ការយល់ឃើញពីអតីតកាល ដោយយុវជនកម្ពុជា អំពីការចងចាំនៃរបបខ្មែរក្រហម” *Cambodia Working Paper Series3/2019*, Swisspeace. https://www.swisspeace.ch/assets/publications/downloads/d15dd63fdc/WP-1-Cambodia-Series-d.pdf

Williams, Timothy, Julie Bernath, Boravin Tann & Somaly Kum. យុត្តិធម៌និងការផ្សះផ្សា សម្រាប់ជនរងគ្រោះខ្មែរក្រហម? ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរការយុត្តិធម៌អន្តរកាល របស់កម្ពុជា Marburg: Centre for Conflict Studies; Phnom Penh: Centre for the Study of Humanitarian Law; Bern: Swisspeace, 2018